**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# គោលការណ៍ណែនាំថ្នាក់ជាតិ
# ស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ

**រៀបចំដោយ**

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**២០២៣**

# អារម្ភកថា

នៅពីរទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ និងកំពុងសមាហរណកម្មខ្លួនចូលក្នុងតំបន់ និងពិភពលោក ដែលធ្វើឱ្យកម្ពុជាទទួលបានឱកាសជាច្រើនក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិ។ ទន្ទឹមនឹងនេះ ដែរកម្ពុជាបានត្រៀមខ្លួនជាស្រេចដើម្បីចូលរួមក្នុងបដិវត្តន៍ឧស្សាហកម្មទី៤ ដែលផ្តោតជាសំខាន់ទៅលើវិស័យបច្ចេកវិទ្យាឌីជីថល ដែលពិភពលោកបាននឹងកំពុងប្រើប្រាស់សម្រាប់វិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច យ៉ាងមានប្រសិទ្ធភាព។ ការរីកចម្រើនផ្នែកបច្ចេកវិទ្យាឌីជីថលបានជំរុញដល់ការរីកលូតលាស់ការងារ នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ចរបស់កម្ពុជា ព្រមទាំងបានបង្កើននូវទំនាក់ទំនងយ៉ាងល្អជាមួយបណ្តាប្រទេសនានាក្នុងតំបន់ និងនៅជុំវិញពិភពលោកថែមទៀតផង។

ស្របគ្នានឹងការរីកចម្រើនផ្នែកបច្ចេកវិទ្យាឌីជីថល ឱកាសនៃការនាំឱ្យមានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញក៏ត្រូវបានកើតមានឡើង និងក្លាយជាទម្រង់ថ្មីមួយ ដែលកំពុងរីករាលដាលនៅលើពិភពលោក រួមទាំងប្រទេសកម្ពុជាផងដែរ។ ការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតទៅនឹងសម្ភារផ្ទាល់ខ្លួន មានដូចជាកុំព្យូទ័រ ទូរស័ព្ទដៃវៃឆ្លាត ឬឧបករណ៍ឌីជីថលដទៃទៀតនៅតាមសហគមន៍ បានផ្តល់នូវអត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចជាច្រើន ប៉ុន្តែទន្ទឹមនោះ ក៏បានបង្កនូវហានិភ័យផងដែរចំពោះកុមារ និងយុវជន ដែលជាអ្នកប្រើប្រាស់ និងចូលរួមសកម្មភាពក្នុងបណ្តាញទំនាក់ទំនងសង្គមនានា។ វិសាលភាព នៃការភ្ជាប់ប្រព័ន្ធអ៊ីនធឺណិតនេះ បានបង្កលក្ខណៈកាន់តែងាយស្រួល និងឆាប់រហ័សដល់អ្នកប្រើប្រាស់ ក្នុងការអាចទទួលបានសម្ភារពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទលើកុមារ។

ដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដោយមានការគាំទ្រពីអង្គការភ្លែនអន្តរជាតិកម្ពុជា និងអង្គការដែនដីមនុស្ស-ប្រទេសហូឡង់ដ៍ សហការជាមួយក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន បានរៀបចំគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញក្នុងគោលបំណង ដើម្បីធានា និងជំរុញឱ្យអ្នកពាក់ព័ន្ធបង្កើតធនធានក្នុងកិច្ចការពារកុមារ ដែលមានគុណវុឌ្ឍិ ភាពបត់បែន និងងាយស្រួលអនុវត្តក្នុងចក្ខុវិស័យ និងការទទួលខុសត្រូវលើកិច្ចការពារអ្នកប្រើប្រាស់ប្រព័ន្ធអនឡាញ ជាពិសេសកុមារ និងយុវជន។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ដែលបានចូលរួមផ្តល់ធាតុចូល និងគាំទ្រក្នុងការរៀបចំគោលការណ៍ណែនាំថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញនេះ ឱ្យដំណើរការទៅយ៉ាងល្អប្រសើរ និងទទួលបានជោគជ័យ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់កុមារ និងយុវជនគ្រប់រូបនៅកម្ពុជា។

ថ្ងៃទីសុក្រ ៥កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣

**ជ.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**ប្រធាន**

**វង_សូត**

# មាតិកា


អារម្ភកថា ..... i

១. សេចក្តីផ្តើម ..... ១

១.២.គោលបំណង ..... ១

១.៣.និយមន័យ ..... ១

១.៤.ទិដ្ឋភាពទូទៅនៃការរីកចម្រើនបច្ចេកវិទ្យាឌីជីថល ..... ១

១.៥.ហានិភ័យតាមប្រព័ន្ធអនឡាញចំពោះកុមារ ..... ៣

១.៦.ទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ..... ៤

- ១.៦.១.ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ ..... ៤
- ១.៦.២.រូបភាព-សម្ភាររំលោភបំពានផ្លូវភេទលើកុមារ ..... ៥
- ១.៦.៣.ការផ្ញើសារបែបផ្លូវភេទ ..... ៥
- ១.៦.៤.ការគំរាមពាក់ព័ន្ធសកម្មភាពផ្លូវភេទ ..... ៥
- ១.៦.៥.ការផ្សាយផ្ទាល់នៃសកម្មភាពកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ..... ៥

១.៧.ប្រភេទក្រុមហ៊ុនបច្ចេកវិទ្យាសារគមនាគមន៍និងព័ត៌មាន ..... ៥

២. គោលការណ៍ណែនាំទូទៅ ..... ៦

២.១.គោលនយោបាយនិងអភិបាលកិច្ច ..... ៦

២.២.យុត្តិធម៌ព្រហ្មទណ្ឌ ..... ៧

២.៣.សេវាជនរងគ្រោះ ..... ៨

២.៤.សង្គម ..... ៩

២.៥.ឧស្សាហកម្ម ..... ១២

២.៦.ប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង ..... ១៣

៣. ការពិនិត្យតាមដាន និងវាយតម្លៃ ..... ១៤

ឯកសារយោង ..... ១៥

## ១. សេចក្តីផ្តើម

គោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ ឆ្លើយតបទៅនឹងតម្រូវការបណ្តាក្រសួង ស្ថាប័នថ្នាក់ជាតិ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធចូលរួមទប់ស្កាត់ហានិភ័យ និងគ្រោះថ្នាក់មួយចំនួនពាក់ព័ន្ធនឹងមាតិកា និងសកម្មភាពខុសច្បាប់ ដែលឧក្រិដ្ឋជនប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានជាមធ្យោបាយ ដូចជាការផលិត កាន់កាប់ ចែកចាយ ឬបញ្ជូននូវរូបភាព ឬសម្ភារ ដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ គោលការណ៍ណែនាំថ្នាក់ជាតិនេះ គោរពតាមសិទ្ធិជាមូលដ្ឋាន និងឧត្តមប្រយោជន៍របស់កុមារ ដោយផ្តល់ជាធាតុចូល និងជាផែនទីសម្រាប់ក្រសួង ស្ថាប័ន វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ដើម្បីពិនិត្យ និងបន្តបង្កើតគោលការណ៍ណែនាំកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញសម្រាប់វិស័យទទួលបន្ទុក។

## ១.២. គោលបំណង

គោលការណ៍ណែនាំថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញមានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីហានិភ័យ និងផ្តល់ជាអភិក្រមបរិយាបន្នរួមមួយក្នុងការឆ្លើយតបចំពោះការគំរាមកំហែង និងគ្រោះថ្នាក់ ដែលកុមារអាចជួបប្រទះនៅក្នុង និងក្រៅប្រព័ន្ធអនឡាញ។

## ១.៣. និយមន័យ

**ការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ** សំដៅទៅលើការប្រើប្រាស់អ៊ីនធឺណិត ឬបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(ICT) ជាមធ្យោបាយ ដើម្បីសម្រួលដល់ការកេងប្រវ័ញ្ចផ្លូវភេទកុមារ។ ក្នុងនោះរួមមានសកម្មភាពទាំងឡាយណា ដែលមានលក្ខណៈកេងប្រវ័ញ្ចផ្លូវភេទកុមារ និងមានទំនាក់ទំនងជាមួយបរិស្ថានអនឡាញ ឬការប្រើប្រាស់ ICT ណាមួយ ដែលនាំឱ្យមានការកេងប្រវ័ញ្ចផ្លូវភេទ ឬបណ្តាលឱ្យកុមារត្រូវបានកេងប្រវ័ញ្ចផ្លូវភេទ។

**បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន** (ICT/Information and Communications Technology) ត្រូវបានកំណត់ថាជាសំណុំឧបករណ៍ និងធនធានបច្ចេកវិទ្យាចម្រុះ ដែលប្រើដើម្បីបញ្ជូន រក្សាទុក បង្កើត ចែករំលែក ឬផ្លាស់ប្តូរព័ត៌មាន។

**យូអរអិល** (URL/Uniform Resource Locator)ជាអាសយដ្ឋានធនធាន ឯកសារ កម្មវិធី ឬគេហទំព័រនៅលើបណ្តាញកុំព្យូទ័រ ឬអ៊ីនធឺណិត ដែលបង្ហាញទីតាំង និងជាយន្តការសម្រាប់ទាញយកទិន្នន័យជាក់លាក់។ **យូអរអិល** ជាប្រភេទជាក់លាក់នៃ**យូអរអាយ** (URI/Uniform Resource Identifier) ដែលមនុស្សជាច្រើនប្រើពាក្យទាំងពីរជំនួសគ្នា។

## ១.៤. ទិដ្ឋភាពទូទៅនៃការរីកចម្រើនបច្ចេកវិទ្យាឌីជីថល

នៅអំឡុងពីរទសវត្សរ៍ចុងក្រោយនេះ ប្រទេសកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចជាបន្តបន្ទាប់ និងកំពុងសមាហរណកម្មខ្លួនចូលក្នុងតំបន់ និងពិភពលោក ដែលធ្វើឱ្យកម្ពុជាទទួលបានឱកាសជាច្រើនក្នុងការ

កសាង និងអភិវឌ្ឍប្រទេសជាតិ។ ស្របពេលជាមួយគ្នានេះ រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភាបានដាក់ចេញនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ដោយធ្វើការវិភាជន៍ធនធានបន្ថែមលើវិស័យសុខាភិបាល អប់រំ សង្គមកិច្ច និងវិស័យផ្សេងៗទៀត ដើម្បីជំរុញការអភិវឌ្ឍធនធានមនុស្ស រួមទាំងការអភិវឌ្ឍកុមារសំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព២០១៦-២០៣០។ ទន្ទឹមនេះ កម្ពុជាក៏បានត្រៀមខ្លួនរួចជាស្រេចក្នុងការចូលរួមក្នុងបដិវត្តឧស្សាហកម្មទី៤ ដែលផ្តោតជាពិសេសលើវិស័យបច្ចេកវិទ្យាឌីជីថល ដែលពិភពលោកកំពុងប្រើប្រាស់សម្រាប់វិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច យ៉ាងមានប្រសិទ្ធភាព។

ការរីកចម្រើនផ្នែកបច្ចេកវិទ្យាឌីជីថល និងមានតម្លៃសេវាសមរម្យ បានបង្កភាពងាយស្រួលក្នុងការភ្ជាប់ប្រព័ន្ធអនឡាញនៅលើកុំព្យូទ័រផ្ទាល់ខ្លួន ទូរស័ព្ទដៃវៃឆ្លាត និងឧបករណ៍ឌីជីថលដទៃទៀត។ ទន្ទឹមនឹងនេះ អំណោយផលនៃការផ្ទេរទិន្នន័យទំហំធំ និងមានល្បឿនលឿន បានធ្វើឱ្យទំនាក់ទំនងប្រចាំថ្ងៃកាន់តែប្រសើរឡើងក្នុងចំណោមអ្នកប្រើប្រាស់ទូទៅ ជាពិសេសកុមារ និងយុវជន។ ប៉ុន្តែការទទួលបានសេវាកម្មអនឡាញកាន់តែទូលំទូលាយ និងកាន់តែងាយស្រួលនេះ ក៏បានបង្កនូវបញ្ហាប្រឈមនានាគួរឱ្យកត់សម្គាល់ផងដែរ ចំពោះសុវត្ថិភាពកុមារ និងយុវជន ទាំងនៅក្នុងនិងក្រៅប្រព័ន្ធអនឡាញ អំពីបញ្ហាឯកជនភាព និងការរំលោភបំពាន ដូចជា ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ(Online Grooming) រូបភាព-សម្ភាររំលោភបំពានផ្លូវភេទលើកុមារ (CSAM) ការផ្ញើសារបែបផ្លូវភេទ (Sexting) ការគំរាមពាក់ព័ន្ធសកម្មភាពផ្លូវភេទ (Sextortion) និងការផ្សាយផ្ទាល់នៃសកម្មភាពរំលោភបំពានផ្លូវភេទលើកុមារ (Live online child sexual abuse)និងទម្រង់ផ្សេងទៀត នៃការរំលោភបំពានតាមប្រព័ន្ធអនឡាញ ដែលជាហានិភ័យយ៉ាងធ្ងន់ធ្ងរសម្រាប់កុមារ និងយុវជន នៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។

ប្រជាជនទូទាំងពិភពលោកជាងពាក់កណ្តាល បានប្រើប្រាស់ប្រព័ន្ធអនឡាញគឺស្មើ ៥៣,៦% ស្មើនឹងចំនួនប្រមាណ ៤,១៣ពាន់លាននាក់ ដោយរួមទាំងកម្ពុជាផង ក្នុងនោះមានអ្នកប្រើប្រាស់ប្រព័ន្ធអនឡាញម្នាក់ក្នុងចំណោមបីនាក់ គឺជាកុមារអាយុក្រោម ១៨ឆ្នាំ។[1] នៅឆ្នាំ២០១៩ IWF បានចាត់វិធានការលើគេហទំព័រចំនួន ១៣២,៦៧៦ ដែលត្រូវបានបញ្ជាក់ថា មានការរំលោភបំពានផ្លូវភេទកុមារ ដោយយូអិល (URL) មួយអាចមានរូបថត ឬ វីដេអូរាប់រយ។ ក្នុងចំណោមរូបថតដែល IWF បានចាត់វិធានការ ៤៥% នៃរូបថតទាំងនោះបានបង្ហាញអំពីកុមារអាយុ ១០ឆ្នាំ ឬក្មេងជាងនេះ ហើយគេហទំព័រចំនួន ១,៦០៩ បង្ហាញអំពីកុមារអាយុ ០-២ឆ្នាំ ក្នុងចំណោមនោះ ៧១% បង្ហាញពីការរំលោភបំពានផ្លូវភេទធ្ងន់ធ្ងរដូចជា ការរំលោភសេពសន្ថវៈ និងទារុណកម្មផ្លូវភេទ។

ដើម្បីកាត់បន្ថយហានិភ័យ នៃបច្ចេកវិទ្យាឌីជីថល និងដោយមើលឃើញបញ្ហាប្រឈម និងផលប៉ះពាល់ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ប្រទេសកម្ពុជាបានចូលជារដ្ឋភាគីហត្ថលេខី នៃសេចក្តីថ្លែងការណ៍សកម្មភាពសកល(WePROTECT) និងបានចូលជាសមាជិក នៃប្រទេសភាពជាដៃគូ

[1] S., Carr, J., and Byrne, J. (2015) One in three: The task for global internet governance in addressing children's rights. Global Commission on Internet Governance: Paper Series. London: CIGI and Chatham House, https://www.cigionline.org/publications/one-three-internet-governance-and-childrens-rights

សកល ដើម្បីលុបបំបាត់អំពើហិង្សាលើកុមារ ដោយចូលរួមអនុវត្តយុទ្ធសាស្ត្រ INSPIRE។ ប្រមុខរាជរដ្ឋាភិបាលកម្ពុជាក៏បានចូលរួមអនុម័តលើសេចក្តីថ្លែងការណ៍ នាកិច្ចប្រជុំកំពូលនៅឆ្នាំ២០១៩ ក្នុងគោលបំណងអំពាវនាវឱ្យរដ្ឋជាសមាជិកអាស៊ានទាំងអស់ប្រើប្រាស់បទដ្ឋានកម្រិតខ្ពស់ ដើម្បីការពារកុមារនៅក្នុងអាស៊ានពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានចេញរបាយការណ៍វិភាគស្ថានភាពដំបូង ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទ និងផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ។

ឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងផ្អែកលើសេចក្តីថ្លែងការណ៍សកម្មភាពសកលដែលបានបង្កើតយន្តការគំរូនៃការឆ្លើយតបថ្នាក់ជាតិ (MNR) ដែលសង្កត់ធ្ងន់លើសារសំខាន់នៃការចូលរួមរបស់អ្នកពាក់ព័ន្ធនានា និងការកំណត់នូវឧស្សាហកម្មពាក់ព័ន្ធធំៗនៅក្នុងកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ និងគោលការណ៍ណែនាំសម្រាប់ឧស្សាហកម្មស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ ដែលរៀបចំឡើងដោយសហភាពទូរគមនាគមន៍អន្តរជាតិ(ITU) និងសៀវភៅណែនាំ និងឧបករណ៍គំរូសកលស្តីពីកិច្ចការពារតាមប្រព័ន្ធអនឡាញ ព្រមទាំងឯកសារពាក់ព័ន្ធ និងដោយពិនិត្យឃើញនូវភាពខ្វះចន្លោះ នៃគោលការណ៍រួមថ្នាក់ជាតិ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល រៀបចំគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។

## ១.៥. ហានិភ័យតាមប្រព័ន្ធអនឡាញចំពោះកុមារ

ក្របខ័ណ្ឌច្បាប់ចាំបាច់ត្រូវដឹងច្បាស់អំពីអ្វី ដែលបង្កអន្តរាយខុសច្បាប់ ជាពិសេសហានិភ័យ និងគ្រោះថ្នាក់ពាក់ព័ន្ធនឹងមាតិកា និងសកម្មភាពខុសច្បាប់។ អ្នកផ្តល់សេវាត្រូវរំពឹងថា នឹងទប់ស្កាត់រាល់សកម្មភាពខុសច្បាប់ ដែលកើតចេញពីសេវាកម្មរបស់ពួកគេ ដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់យុវជន ហើយត្រូវចាត់វិធានការរហ័សប្រសិនបើមានបញ្ហាកើតឡើង។ អាកប្បកិរិយា និងសកម្មភាពមួយចំនួន(ដូចជាការលេងល្បែង ឬការមើលរូបអាសអាភាស) មានលក្ខណៈស្របច្បាប់សម្រាប់មនុស្សពេញវ័យ ប៉ុន្តែទង្វើនេះ គឺជាការបង្កហានិភ័យដល់កុមារ និងយុវជន ហើយគ្រោះថ្នាក់ខ្លះបង្កការពិបាកសម្រាប់យុវជន(ដូចជា អ្នកដែលលើកកម្ពស់ការរំលោភបំពាន ហឹង្សា ឬធ្វើអត្តឃាត) ប៉ុន្តែកុមារទទួលបានកិច្ចការពារខ្ពស់ជាងមុនក្នុងការទទួលស្គាល់សិទ្ធិ និងភាពងាយរងគ្រោះ ដែលទាក់ទងនឹងអាយុ។ ប្រភេទនៃបញ្ហាទាំងនេះ មិនមានដូចគ្នានៅទូទាំងតំបន់ និងប្រទេសនោះទេ ប៉ុន្តែក្នុងករណីនីមួយៗ សេវាកម្មត្រូវបានរំពឹងថា នឹងមានភាពសកម្មក្នុងការទប់ស្កាត់មិនឱ្យប៉ះពាល់ដល់យុវជន។ នៅពេលពិចារណាពីគ្រោះថ្នាក់ ការសង្កត់ធ្ងន់លើគ្រោះថ្នាក់គឺការរកដំណោះស្រាយដល់ទីបំផុត។ ក្របខ័ណ្ឌនេះ មិនយល់ច្បាស់ពីបទពិសោធន៍របស់យុវជន។ តាមពិតមានយុវជនតិចតួចណាស់ ដែលទទួលរងគ្រោះថ្នាក់ធ្ងន់ធ្ងរ ប៉ុន្តែទន្ទឹមនេះ ក៏មានយុវវ័យរាប់លាននាក់ជួបប្រទះនឹងគ្រោះមហន្តរាយជាច្រើន និងទទួលរងផលប៉ះពាល់តាមរបៀបផ្សេងៗគ្នា ដែលជាការគ្រួសត្រាយផ្លូវឆ្ពោះទៅរកគ្រោះថ្នាក់ធ្ងន់ធ្ងរ។

ភស្តុតាងបង្ហាញថា កុមារប្រឈមនឹងហានិភ័យតាមប្រព័ន្ធអនឡាញ មិនអាស្រ័យលើទីតាំងភូមិសាស្ត្រ

ទេ ព្រោះពួកគេប្រើប្រាស់សេវាកម្មដូចគ្នា ប៉ុន្តែស្ថិតក្នុងបរិបទខុសគ្នា ហើយអាចបង្កការព្រួយបារម្ភជាច្រើន។ ជារឿយៗ គ្រោះថ្នាក់ក្នុងប្រព័ន្ធអនឡាញ និងក្រៅប្រព័ន្ធអនឡាញមានទំនាក់ទំនងជិតស្និទ្ធនឹងគ្នា ហើយហានិភ័យទាំងនេះតែងតែមានការត្រួតគ្នា។ បរិយាកាសតាមប្រព័ន្ធអនឡាញកំពុងវិវត្តយ៉ាងឆាប់រហ័ស ប៉ុន្តែហានិភ័យ និងគ្រោះថ្នាក់មួយចំនួនមិនទាន់លេចចេញជារូបរាងនៅឡើយទេ។ ការពិចារណាលើកស្ទួតាង នៃគ្រោះមហន្តរាយពីជុំវិញពិភពលោកគឺជាការចាំបាច់ ដែលជួយឱ្យយើងដឹងពីបញ្ហា និងហានិភ័យជាក់លាក់ នៅពេលដែលបញ្ហាទាំងនេះ បង្ហាញនៅក្នុងបរិបទជាតិ ឬតំបន់ យើងនឹងអាចប្រមើលមើលដឹងពីហានិភ័យ ដែលអាចនឹងកើតឡើងនាពេលអនាគត។ បណ្តាញពហុវិស័យបើកចំហ និងពិគ្រោះយោបល់អាចចែករំលែកព័ត៌មាន និងជួយកំណត់អត្តសញ្ញាណគ្រោះមហន្តរាយថ្មីៗ និងកំពុងលេចចេញ។ ហានិភ័យចែកជាបួនប្រភេទធំៗ ដែលត្រូវបានគេស្គាល់ថាជា4C៖

- **ហានិភ័យនៃមាតិកា** រួមមាន រូបភាពមិនសមរម្យរបស់កុមារ រូបភាពអាសអាភាសមនុស្សពេញវ័យ មាតិកាមានលក្ខណៈរើសអើង ឬការស្អប់ខ្ពើម ព័ត៌មានក្លែងក្លាយ ឬការពិពណ៌នាមិនពិត មាតិកាដែលជម្រុញឥរិយាបថប្រថុយប្រថាន ឬមិនល្អ។
- **ហានិភ័យនៃការទំនាក់ទំនង** រួមមាន ការជួញដូរកុមារ ការរំលោភបំពាន ការរើសអើង និងការនិយាយ បែបស្អប់ខ្ពើម ការលួងលោម និងការកេងប្រវ័ញ្ច។
- **ហានិភ័យនៃការប្រព្រឹត្ត** រួមមាន ការសម្លុតគំរាមកំហែងផ្លូវភេទ ការគំរាមកំហែង និងការបំភិតបំភ័យ ការបង្ខូចកេរ្តិ៍ឈ្មោះ ការបំបាក់មុខក្នុងសង្គម។.
- **ហានិភ័យនៃកិច្ចសន្យា**(ពេលខ្លះហៅថាហានិភ័យពាណិជ្ជកម្ម) រួមមាន ការប្រមូលទិន្នន័យ សម្រាប់ការផ្សាយពាណិជ្ជកម្ម ការបន្លំ ការបោកប្រាស់ ការប្រើមិនត្រឹមត្រូវនៃកម្មសិទ្ធិបញ្ញា។

## ១.៦. ទម្រង់ នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ

ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ សំដៅលើរាល់ទង្វើនៃការកេងប្រវ័ញ្ចផ្លូវភេទដែលអាចកើតឡើងចំពោះកុមារតាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញ។ ឧក្រិដ្ឋជនប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ជាមធ្យោបាយដើម្បីទទួលបានការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ឬបណ្តាលឱ្យកុមារត្រូវគេកេងប្រវ័ញ្ចផ្លូវភេទ ឬក៏ជាមធ្យោបាយក្នុងការផលិត កាន់កាប់ ចែកចាយ ឬបញ្ជូននូវរូបភាព ឬសម្ភារដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ទម្រង់ទូទៅ នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញមានដូចខាងក្រោម៖

### ១.៦.១.ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ

ការលួងលោមកុមារតាមប្រព័ន្ធអនឡាញ(Online Grooming)សំដៅទៅលើសកម្មភាពដែលព្យាយាមទាក់ទងកុមារតាមប្រព័ន្ធអនឡាញ ដើម្បីកសាងទំនុកចិត្តក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ។ ការលួងលោមទាំងនោះរួមមាន៖ ការបង្ហាញនូវសម្ភារអាសអាភាស ដូចជា តាមរយៈការផ្ញើនូវមាតិកា សារ វីដេអូ ឬរូបភាព

បែបផ្លូវភេទទៅកាន់កុមារ។ វិធីទាំងនេះ អាចបន្សាំកុមារទៅនឹងរឿងរ៉ាវផ្លូវភេទក្នុងគោលបំណងបង្កើនឱកាសឱ្យកុមារបញ្ជូនរូបភាព-សម្ភារអាសអាភាសដោយខ្លួនឯង។

### ១.៦.២.រូបភាព-សម្ភាររំលោភបំពានផ្លូវភេទលើកុមារ

រូបភាព-សម្ភាររំលោភបំពានផ្លូវភេទលើកុមារ (CSAM) សំដៅលើសម្ភារដែលបង្ហាញពីកុមារក្នុងស្ថានភាពអាក្រាត ពិព៌ណនាដោយផ្តោតលើកេរ្តិ៍ភេទរបស់កុមារ ឬសម្ភារដែលព៌ណនាអំពីកុមារនៅក្នុងស្ថានភាពបែបអាសអាភាស។ សម្ភារទាំងនោះរួមមាន៖ រូបភាព វីដេអូ អត្ថបទ និងសារសម្លេង ដែលមានលក្ខណៈបែបអាសអាភាសជាដើម។

### ១.៦.៣.ការផ្ញើសារបែបផ្លូវភេទ

ការផ្ញើសារបែបផ្លូវភេទ(Sexting) គឺជាសកម្មភាពនៃការបញ្ជូន ការទទួលសារ ដែលមានលក្ខណៈផ្លូវភេទ រូបថត វីដេអូផ្លូវភេទ ដែលបង្កើតឡើងដោយខ្លួនឯង ឬបានមកពីអ្នកផ្សេងទៀត ដោយស្ម័គ្រចិត្តតាមរយៈទូរស័ព្ទ ឧបករណ៍ផ្សេងៗ និងកម្មវិធីដែលអាចផ្ញើសារឱ្យគ្នាទៅវិញទៅមកបាន។ សកម្មភាពនេះ អាចនាំឱ្យកើតមានការរំលោភបំពានផ្លូវភេទនៅពេលភាគីណាមួយឈប់ចង់ទទួលបានសារ ឬរូបភាពផ្លូវភេទ ប៉ុន្តែភាគីម្ខាងទៀតនៅតែបន្តផ្ញើ ឬបញ្ជូន។

### ១.៦.៤.ការគំរាមពាក់ព័ន្ធសកម្មភាពផ្លូវភេទ

ការគំរាមពាក់ព័ន្ធសកម្មភាពផ្លូវភេទ(Sextortion) គឺជាទង្វើ ដែលជនល្មើសផ្លូវភេទលើកុមារប្រើប្រាស់សម្ភាររំលោភបំពានផ្លូវភេទ ដែលបានទទួលពីកុមារជាញឹកញាប់តាមរយៈការផ្ញើ ឬការបញ្ជូនរូបភាពអាក្រាត ឬបង្ហាញសកម្មភាពផ្លូវភេទ ដែលបង្កើតឡើងដោយខ្លួនឯង ដើម្បីគំរាមកុមារឱ្យបញ្ជូនរូបថត ឬវីដេអូផ្លូវភេទបន្ថែមទៀតដល់ពួកគេ ដើម្បីជួបផ្ទាល់ក្នុងគោលបំណងផ្លូវភេទ ឬដើម្បីទទួលបាននូវផលប្រយោជន៍ផ្សេងទៀតដូចជា ថវិកា សម្ភារ ឬការគ្រប់គ្រងលើកុមារជាដើម។

### ១.៦.៥.ការផ្សាយផ្ទាល់នៃសកម្មភាពរំលោភបំពានផ្លូវភេទលើកុមារ

ការផ្សាយផ្ទាល់នៃសកម្មភាពរំលោភបំពានផ្លូវភេទលើកុមារ (Live online child sexual abuse) សំដៅលើការផ្សាយផ្ទាល់ នៃសកម្មភាពកេងប្រវ័ញ្ចផ្លូវភេទពាក់ព័ន្ធកុមារ ឬការឱ្យកុមារសម្តែងសកម្មភាពផ្លូវភេទនៅមុខកាមេរ៉ា(អាចក្នុងស្ថានភាពអាក្រាត ឬក្នុងស្ថានភាពផ្លូវភេទ) ដែលភ្ជាប់ទៅនឹងអ៊ីនធឺណិត និងអាចឱ្យអ្នកដទៃចូលទស្សនាបានពីចម្ងាយ ឬតាមប្រព័ន្ធអនឡាញ ក្នុងពេលតែមួយ ។ ពេលខ្លះជនល្មើសផ្លូវភេទលើកុមារ ផ្តល់ជាថវិកា សម្ភារមានតម្លៃដល់កុមារផ្ទាល់ ឬតាមរយៈអ្នកសម្របសម្រួល ឬអន្តរការី ដើម្បីដោះដូរជាមួយនឹងសកម្មភាពនេះ។

## ១.៧. ប្រភេទក្រុមហ៊ុនបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

ក្រុមហ៊ុនបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានទាំងឡាយណា ដែលផ្តល់ផលិតផល និងសេវាកម្មរបស់ខ្លួន ដូចខាងក្រោម៖ **ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ីនធឺណិត** រួមមានសេវាកម្មអ៊ីនធឺណិតតាមខ្សែ ឬឥតខ្សែ ដោយគិតថ្លៃ ឬឥតគិត បណ្តាញទំនាក់ទំនងសង្គម/កម្មវិធីផ្ញើសារ និងកម្មវិធីលេងហ្គេមអនឡាញ។ **រោងចក្រផលិត**

**ហាដវែរ និងកម្មវិធីសូហ្វវែរ** ដូចជាក្រុមហ៊ុនផ្តល់ឧបករណ៍ចល័ត រួមមាន ទូរស័ព្ទចល័ត ឧបករណ៍លេងហ្គេម ឧបករណ៍ជំនួយជាសម្លេងនៅតាមផ្ទះ បរិក្ខារភ្ជាប់អ៊ីនធឺណិត និងប្រដាប់ប្រដាក្មេងលេងដែលភ្ជាប់អ៊ីនធឺណិតបានសម្រាប់កុមារ។ **ក្រុមហ៊ុនដែលផ្តល់សេវាកម្មប្រព័ន្ធផ្សព្វផ្សាយឌីជីថល** (កម្មវិធីបង្កើតមាតិកា ការផ្តល់លទ្ធភាពក្នុងការទទួលបានមាតិកា ឬការបង្ហោះមាតិកា)។ **ក្រុមហ៊ុនដែលផ្តល់សេវាកម្មបញ្ជូនវីដេអូ សម្លេង ឬរូបភាព រួមទាំងការផ្សាយបន្តផ្ទាល់**។ **ក្រុមហ៊ុនដែលផ្តល់សេវាកម្មរក្សាទុកឯកសារឌីជីថល** ក្រុមហ៊ុនផ្តល់សេវាកម្មរក្សាឯកសារនៅតាមប្រព័ន្ធអ៊ីនធឺណិត (បច្ចេកវិទ្យាពពក, ក្លោដ Cloud)។

## ២. គោលការណ៍ណែនាំទូទៅ

កិច្ចការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជាប្រឈមទៅនឹងបញ្ហាមួយចំនួនដូចជា៖ ១.កង្វះចំណេះដឹងអំពីឧបករណ៍បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(ICT) និងការវិវឌ្ឍដ៏លឿននៃបច្ចេកវិទ្យា ២.កង្វះធនធាននៅសហគមន៍មូលដ្ឋាន ៣.កង្វះកិច្ចសហការជាមួយអ្នកមានជំនាញឯកទេស និងធនធានជាតិ ៤.ភាពពឹងផ្អែកជ្រុលលើវិធីសាស្ត្រស៊ើបអង្កេតផ្ទាល់បែបប្រពៃណី ៥.កង្វះអភិក្រមដែលគិតគូរអំពីជនរងគ្រោះ។ ដើម្បីដោះស្រាយបញ្ហាការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយ ឆ្លើយតបចំពោះសមត្ថភាពនានា ដែលត្រូវបានកំណត់នៅក្នុងក្របខ័ណ្ឌគំរូនៃការឆ្លើយតបថ្នាក់ជាតិរបស់សេចក្តីថ្លែងការណ៍សកម្មភាពសកល (WePROTECT) ដែលបានចុះហត្ថលេខា ដោយតំណាងរាជរដ្ឋាភិបាលកម្ពុជា នៅឯកិច្ចប្រជុំកំពូលជាសកល នាទីក្រុងអាប៊ុយដាប៊ី កាលពីឆ្នាំ២០១៥។ ការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះការកេងប្រវ័ញ្ចផ្លូវភេទលើកុមារទាមទារឱ្យមានការចូលរួមពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដោយប្រមូលផ្តុំអ្នកពាក់ព័ន្ធជាច្រើនអង្គភាពអន្តរវិជ្ជាជីវៈ និងពហុវិស័យនៃស្ថាប័នទាំងអស់ ដែលមានការទទួលខុសត្រូវចំពោះកិច្ចការពារកុមារនៅក្នុងបរិយាកាសអ៊ីនធឺណិត រួមទាំងសង្គមស៊ីវិល និងឧស្សាហកម្មឯកជន អនុវត្តតាមសេចក្តីថ្លែងការណ៍សកម្មភាពសកល (គំរូនៃការឆ្លើយតបថ្នាក់ជាតិ Model National Response MNR) មាន៖ ១.គោលនយោបាយ និងអភិបាលកិច្ច ២.យុត្តិធម៌ព្រហ្មទណ្ឌ ៣.សេវាជនរងគ្រោះ ៤.សង្គម និងសហគមន៍ ៥.ឧស្សាហកម្ម និង ៦.ប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង។

### ២.១. គោលនយោបាយ និងអភិបាលកិច្ច

២.១.១. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលជាសេនាធិការជូនរាជរដ្ឋាភិបាលលើកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ មានភារកិច្ចសម្របសម្រួល និងត្រួតពិនិត្យការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។

២.១.២. គណៈកម្មការការពារកុមារថ្នាក់ជាតិ និងក្រុមការងារបច្ចេកទេសអន្តរក្រសួងមានភារកិច្ចអភិបាលលើការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ ដើម្បីពិនិត្យ និងផ្តល់យោបល់លើការសិក្សាស្រាវជ្រាវ អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅប្រទេសកម្ពុជា។

២.១.៣. ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ បង្កើន និងជំរុញកិច្ចសហប្រតិបត្តិការក្របខ័ណ្ឌពហុភាគីជាតិ និងអន្តរជាតិ ដើម្បីសម្របសម្រួល និងដោះស្រាយហានិភ័យសម្រាប់កុមារ និងយុវជនតាមប្រព័ន្ធអនឡាញ រួមទាំងយន្តការអនុវត្តច្បាប់ និងបទប្បញ្ញត្តិប្រកបដោយប្រសិទ្ធភាព និងទទួលបានការផ្តល់យោបល់ពីអ្នកជំនាញលើកិច្ចការការពារកុមារតាមប្រព័ន្ធអនឡាញ។

២.១.៤. ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ត្រូវបង្កើត និងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំអំពីសុវត្ថិភាពអ៊ីនធឺណិត ឬកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ ទៅតាមវិស័យរៀងៗខ្លួនស្របតាមគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ និងបទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធ។

២.១.៥. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ដើម្បីធ្វើការសិក្សាស្រាវជ្រាវលើវឌ្ឍនភាពបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ការប្រើប្រាស់របស់កុមារលើបច្ចេកវិទ្យា ហានិភ័យអនឡាញ និងនិន្នាការនៃការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ដើម្បីទទួលបានទិន្នន័យបច្ចុប្បន្នភាព និងភស្តុតាងជាក់លាក់អំពីបញ្ហា និងដើម្បីធានាបាននូវប្រសិទ្ធភាព នៃកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។ ការសិក្សាស្រាវជ្រាវស្តីពីការបញ្ឈប់គ្រោះថ្នាក់ នៃការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញនៅកម្ពុជា ដែលត្រូវបានប្រកាសផ្សព្វផ្សាយជាផ្លូវការនៅខែកញ្ញា ឆ្នាំ២០២២ គឺជាករណីសិក្សាមួយដ៏ល្អអំពីការស្រាវជ្រាវ ដែលត្រូវបន្តអនុវត្ត។

២.១.៦. ក្រសួង ស្ថាប័នពាក់ព័ន្ធ ពិនិត្យលទ្ធភាពលើការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ឬធ្វើវិសោធនកម្មច្បាប់ ដែលពាក់ព័ន្ធ ដើម្បីការពារសុវត្ថិភាពកុមារពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

## ២.២. យុត្តិធម៌ព្រហ្មទណ្ឌ

២.២.១. ក្រសួង ស្ថាប័ន វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ណែនាំបទប្បញ្ញត្តិការពារទិន្នន័យ និងអាជ្ញាធរត្រួតពិនិត្យឯករាជ្យត្រូវធានាថា ទិន្នន័យរបស់កុមារត្រូវបានការពារ និងប្រមូលបានតែក្នុងករណីចាំបាច់ជាមួយនឹងសុវត្ថិភាពកម្រិតខ្ពស់។

២.២.២. ក្រសួង ស្ថាប័ន និងមន្ត្រីនគរបាលយុត្តិធម៌ ពង្រឹងការស៊ើបអង្កេតបទល្មើសផ្លូវភេទប្រឆាំងកុមារតាមប្រព័ន្ធអនឡាញ និងជំរុញការផ្តន្ទាទោសជនល្មើសស្របតាមច្បាប់ និងយុត្តិធម៌។

២.២.៣. ក្រសួង ស្ថាប័ន និងមន្ត្រីនគរបាលយុត្តិធម៌ ពង្រឹងប្រព័ន្ធយុត្តិធម៌កុមារមេត្រី និងការអនុវត្តឱ្យមានភាពម៉ឺងម៉ាត់នៅគ្រប់ករណីពាក់ព័ន្ធជនរងគ្រោះជាកុមារ ដើម្បីកាត់បន្ថយផលប៉ះទង្គិចផ្លូវចិត្ត ឬការរងគ្រោះឡើងវិញចំពោះកុមារ ដែលចូលរួមក្នុងដំណើរការនីតិវិធីផ្លូវច្បាប់ ទាំងក្នុង

ដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ចៅក្រមស៊ើប និងដំណាក់កាលជំនុំជម្រះនៅតុលាការ។

២.២.៤. ក្រសួង ស្ថាប័ន ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងកែលម្អចំណុចខ្វះខាតក្នុងការអនុវត្ត និងប្រព័ន្ធតុលាការ ដើម្បីបង្កើនការយល់ដឹងអំពីបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ យន្តការរាយការណ៍ និងការផ្តន្ទាទោសឱ្យមានប្រសិទ្ធភាព។

២.២.៥. ក្រសួង ស្ថាប័ន បង្កើតដំណើរការគ្រប់គ្រងករណីហានិភ័យជនល្មើស និងអ្នកពាក់ព័ន្ធពហុភាគីឱ្យមានប្រសិទ្ធិភាពផ្អែកលើការអនុវត្តល្អ នៃបទដ្ឋានអន្តរជាតិ។

២.២.៦. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ បង្កើតប្រព័ន្ធមូលទិន្នន័យ(Database)សម្រាប់ករណីនៃការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ប្រកបដោយនិរន្តរភាព និងប្រើប្រាស់ប្រព័ន្ធមូលទិន្នន័យនេះ ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ និងគាំទ្រដល់ការស៊ើបអង្កេតបទល្មើស។ គួរពិចារណាភ្ជាប់ជាមួយមូលទិន្នន័យគ្រប់គ្រងករណីកេងប្រវ័ញ្ចផ្លូវភេទកុមារអន្តរជាតិ (International Child Sexual Exploitation Database or ICSE Database) របស់ស្ថាប័ន INTERPOL និងផ្តល់សច្ចាប័នលើពិធីសារ និងសន្ធិសញ្ញាអន្តរជាតិ និងតំបន់ពាក់ព័ន្ធ។

## ២.៣. សេវាជនរងគ្រោះ

២.៣.១. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធរៀបចំបង្កើត និងបង្កើនកញ្ចប់សេវាគាំពារដល់កុមាររងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដែលចូលរួមក្នុងដំណើរការនីតិវិធីច្បាប់ និងផ្តល់សេវាប្រឹក្សាយោបល់ និងស្តារនីតិសម្បទា និងសមាហរណកម្មកុមាររងគ្រោះដោយសារទៅគ្រួសារ និងសហគមន៍វិញ។

២.៣.២. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ ផ្តល់ជំនួយគាំទ្រដល់ជនរងគ្រោះ និងគ្រួសារ រួមមានការផ្តល់ប្រឹក្សាយោបល់ផ្លូវចិត្ត សុខុមាលភាព ជម្រកសុវត្ថិភាពក្នុងករណីចាំបាច់ ការថែទាំសុខភាព និងផ្លូវច្បាប់ ជាពិសេសក្នុងកំឡុងពេលចូលរួមដំណើរការនីតិវិធីតុលាការ។

២.៣.៣. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ បង្កើត និងពង្រឹងសមត្ថភាពគ្រូបង្គោល បណ្តាញរាយការណ៍បន្ទាន់តាមអ៊ីនធឺណិត និងប្រព័ន្ធទូរស័ព្ទជំនួយកុមារ សម្រាប់ករណីរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងផ្តល់សេវាពិគ្រោះយោបល់តាមទូរស័ព្ទ និងព័ត៌មានអំពីការការពារខ្លួនពីហានិភ័យតាមប្រព័ន្ធអនឡាញដល់កុមាររងគ្រោះ និងងាយរងគ្រោះ។

២.៣.៤. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ បញ្ចូលមេរៀន ឬខ្លឹមសារអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញក្នុងកម្មវិធីបណ្តុះបណ្តាលសម្រាប់កម្លាំងសេវាសង្គម កិច្ចការពារកុមារ និងអ្នកពាក់ព័ន្ធ ឱ្យមានសមត្ថភាពសម្របសម្រួល និងផ្តល់សេវាគាំទ្រដល់កុមាររងគ្រោះ។

២.៣.៥ ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ បញ្ចូលខ្លឹមសារកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ក្នុងកម្មវិធីបណ្តុះបណ្តាលដល់សិស្សមធ្យមវិចិត្រសិល្បៈ និងអ្នកសារព័ត៌មាន។

២.៣.៦. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ បង្កើតយន្តការទាមទារសំណងដែលមានលក្ខណៈងាយស្រួល និងសម្របសម្រួលការទទួលបានសំណងជំងឺចិត្ត និងសំណងបដិទានដល់កុមាររងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ តាមច្បាប់ដែលបានកំណត់ និងជួយកុមាររងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដើម្បីរៀបចំពាក្យបណ្តឹង និងសម្របសម្រួលក្នុងដំណើរការនីតិវិធីច្បាប់។

២.៣.៧. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ បង្កើតក្របខ័ណ្ឌការពារជនរងគ្រោះ ដោយត្រូវគិតគូរពីតម្រូវការសិទ្ធិ និងឧត្តមប្រយោជន៍ និងបង្កើតមជ្ឈមណ្ឌលច្រកចេញចូលតែមួយ ដើម្បីសម្រួលដល់ការអនុវត្តនីតិវិធីការពារកុមារនៅគ្រប់ដំណាក់កាលនៃការផ្តល់សេវា។

២.៣.៨. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធជានាថាបទដ្ឋានប្រតិបត្តិ ដែលផ្តោតលើឧត្តមប្រយោជន៍កុមារត្រូវបានណែនាំឱ្យអនុវត្តយ៉ាងតឹងរឹងនៅពេលគ្រប់គ្រងករណីកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទពាក់ព័ន្ធនឹងកុមារ ដើម្បីកាត់បន្ថយហានិភ័យនៃការរងគ្រោះឡើងវិញ ឬការប៉ះទង្គិចផ្លូវចិត្តសាជាថ្មី។

២.៣.៩. ក្រសួងសុខាភិបាលលើកកម្ពស់ការយល់ដឹង អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅក្នុងចំណោមថ្នាក់ដឹកនាំសុខាភិបាលថ្នាក់រាជធានី ខេត្ត និងផ្តល់សេវាព្យាបាលផ្នែករាងកាយ និងផ្លូវចិត្តដល់កុមាររងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

## ២.៤. សង្គម

២.៤.១. សាលារៀន និងសហគមន៍ ត្រូវតែងតាំង ឬជ្រើសរើសអ្នកដឹកនាំកិច្ចការពារកុមារដែលទទួលបានការបណ្តុះបណ្តាលស្តីពីនីតិវិធីការពារកុមារតាមប្រព័ន្ធអនឡាញ និងរាយការណ៍អំពីករណីរងគ្រោះទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

២.៤.២. ក្រសួង ស្ថាប័ន វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ លើកកម្ពស់ការអប់រំឌីជីថលដែលអាចចូលប្រើបាន ដោយផ្សព្វផ្សាយខ្លឹមសារ រួមទាំងកម្មវិធីពីគ្នាទៅវិញទៅមក ដែលត្រូវបានរចនា ដើម្បីជួយកុមារអភិវឌ្ឍជំនាញឌីជីថល និងផ្តល់សិទ្ធិអំណាចដល់កុមារក្នុងការកសាងសហគមន៍ប្រកបដោយការគោរព ដែលគាំទ្រដល់កិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ។

២.៤.៣. ក្រសួង ស្ថាប័ន វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សព្វផ្សាយខ្លឹមសារអប់រំ នៅពេលដែលការវិវឌ្ឍន៍ឌីជីថលកាន់តែរីកចម្រើន សិស្ស និងគ្រូនឹងត្រូវបានបង្រៀនជំនាញចាំបាច់

សម្រាប់ការប្រាស្រ័យទាក់ទងជាមួយប្រព័ន្ធឌីជីថល ដើម្បីទទួលបានអត្ថប្រយោជន៍ពេញលេញពីខ្លឹមសារកម្មវិធីសិក្សាថ្នាក់ជាតិ និងអន្តរជាតិ។

២.៤.៤. ក្រសួង ស្ថាប័ន វិស័យឯកជន និងអ្នកពាក់ព័ន្ធលើកកម្ពស់អក្ខរកម្មទិន្នន័យត្រូវបានណែនាំនៅទូទាំងកម្មវិធីសិក្សារបស់សាលា និងកម្មវិធីអប់រំកុមារអំពីវិធី ដែលទិន្នន័យរបស់ពួកគេអាចត្រូវបានប្រើប្រាស់ និងផ្តល់នូវការយល់ដឹងជាមូលដ្ឋាន និងលើកទឹកចិត្តដល់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលប្រកបដោយភាពវិជ្ជមាន ស្វ័យភាព និងច្នៃប្រឌិតដោយកុមារ។

២.៤.៥. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ កំណត់នូវហានិភ័យ អត្ថប្រយោជន៍ និងលទ្ធផលសង្គម នៃការប្រើប្រាស់បច្ចេកវិទ្យា រួមទាំងវិធានការការពារ និងបង្ការត្រូវបានផ្សព្វផ្សាយ និងអនុវត្តយ៉ាងទូលំទូលាយ ហើយការអប់រំអក្ខរកម្មទិន្នន័យ ត្រូវធ្វើឱ្យច្បាស់ចំពោះភាគីពាក់ព័ន្ធដែលទទួលខុសត្រូវចំពោះសុវត្ថិភាពអ៊ីនធឺណិត។

២.៤.៦. ក្រសួង ស្ថាប័ន វិស័យឯកជន សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធអប់រំកុមារ ឪពុកម្តាយ អាណាព្យាបាលអំពីហានិភ័យ នៃព័ត៌មានមិនពិតតាមអ៊ីនធឺណិតត្រូវបានបញ្ចូលទៅក្នុងការអប់រំអក្ខរកម្មឌីជីថល។ នេះគួរតែរួមបញ្ចូលការអប់រំទូលំទូលាយ ដើម្បីលើកកម្ពស់ការយល់ដឹង និងការយល់ដឹងអំពីសិទ្ធិមនុស្ស ជាពិសេសសិទ្ធិរបស់កុមារ និងវិធីដែលពួកគេធ្វើការក្នុង និងក្រៅប្រព័ន្ធអនឡាញ។

២.៤.៧. ឪពុកម្តាយ អ្នកអាណាព្យាបាល និងសមាជិកក្រុមគ្រួសារ មិនត្រូវមានភាពខ្មាស់អៀនក្នុងការនិយាយអំពីបញ្ហាផ្លូវភេទជាមួយកូននោះទេ ពីព្រោះមានសារៈសំខាន់ណាស់ក្នុងការបង្ការគ្រោះថ្នាក់ ដែលអាចកើតមាន។ ប្រសិនបើ មានការសង្ស័យអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញកើតឡើងចំពោះកូនអ្នកគួរតែអនុវត្តដូចខាងក្រោម៖

- ស្តាប់ដោយយកចិត្តទុកដាក់ មិនវិនិច្ឆ័យ និងត្រូវមានភាពហ្មត់ចត់ចំពោះអ្វីដែលកូនអ្នកប្រាប់
- លើកទឹកចិត្តកូនរបស់អ្នកឱ្យនិយាយអំពីរឿងរ៉ាវដែលកើតឡើង និងស្វែងរកឪពុកម្តាយ ឬបងប្អូនឱ្យជួយ គឺជារឿងដែលត្រឹមត្រូវបំផុត
- ប្រាប់កូនអ្នកថា នេះមិនមែនជារឿងដែលត្រូវខ្មាស់អៀនទេ ចំពោះការប្រាប់រឿងរ៉ាវដែលបានកើតឡើង ហើយរាល់ការប្រព្រឹត្តគឺជាកំហុស និងជាការទទួលខុសត្រូវរបស់ជនល្មើស
- ប្រាប់កូនអ្នកថា ឪពុកម្តាយ អ្នកអាណាព្យាបាល និងសមាជិកក្រុមគ្រួសារ មិនស្តីបន្ទោសកូនចំពោះកំហុសនេះទេ គឺមានតែអាណិតអាសូរ និងផ្តល់ការគាំទ្រនានា ចំពោះកូនទៅវិញដែលកូនបានជួបរឿងបែបនេះ។

២.៤.៨. អាណាព្យាបាល និងសមាជិកក្រុមគ្រួសារនីមួយៗ ត្រូវតែស្វែងយល់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហានិភ័យអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ត្រូវប្រុងប្រយ័ត្នដូចខាងក្រោម៖

- កុមារមិនត្រូវបានគេស្តីបន្ទោស ចំពោះករណីរំលោភបំពានឡើយ បើទោះបីជាពួកគេបាន

ចូលរួមមកក្នុងសកម្មភាពនោះក៏ដោយ

- ករណីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារពេលខ្លះ មិនកើតឡើងតាមរយៈការជួបប្រាស្រ័យទាក់ទងផ្ទាល់ជាមួយកុមារ និងជនល្មើសក៏ដោយ តែវានៅតែអាចបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់កុមារ ដូចជាការជួបផ្ទាល់ផងដែរ
- ការផ្តល់ប្រាក់កាស វត្ថុមានតម្លៃ ឬអំណោយផ្សេងៗជាថ្នូរនឹងការចូលរួមរបស់កុមារក្នុងសកម្មភាពផ្លូវភេទគឺជាការកេងប្រវ័ញ្ច
- កុមារា និងកុមារីអាចត្រូវបានគេកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ហើយជនល្មើសផ្លូវភេទភាគច្រើនជាមនុស្សដែលកុមារស្គាល់ និងទុកចិត្ត
- ការបង្ការ និងទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញត្រូវចាប់ផ្តើមដោយការប្រាស្រ័យទាក់ទងដោយបើកចំហ ហើយមិនគួរហាមកុមារប្រើប្រាស់ប្រព័ន្ធអនឡាញនេះទេ
- កុមារគ្រប់វ័យសុទ្ធតែអាចប្រឈមមុខ និងជួបប្រទះហានិភ័យនៃការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញដូចនេះត្រូវពិភាក្សា ឬណែនាំកុមារដោយផ្ទាល់អំពីសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញគួរតែចាប់ផ្តើមតាំងពីពេលពួកគេមានអាយុតិច និងជាពិសេសនៅពេលដែលពួកគេចាប់ផ្តើមប្រើប្រាស់ប្រព័ន្ធអនឡាញលើកដំបូង។

២.៤.៩. កុមារមានសិទ្ធិទទួលបានការអប់រំណែនាំពីបញ្ហានានា ដែលប៉ះពាល់ជាអវិជ្ជមានដល់ពួកគេ ហើយទស្សនៈរបស់កុមារ និងយុវវ័យអំពីហានិភ័យ និងគ្រោះថ្នាក់ អត្ថប្រយោជន៍ និងឱកាសនៅក្នុងបរិយាកាសអនឡាញអាចមានភាពខុសប្លែកគ្នា ឬចំពោះមនុស្សពេញវ័យនៅជុំវិញពួកគេ។

២.៤.១០. កុមារគួរតែយល់ដឹងពីហានីភ័យដែលអាចកើតមានឡើងតាមប្រព័ន្ធអនឡាញដូចជាៈ ការល្បួងលោមកុមារតាមប្រព័ន្ធអនឡាញ រូបភាព-សម្ភាររំលោភបំពានផ្លូវភេទលើកុមារ ការផ្ញើសារបែបផ្លូវភេទ ការគំរាមបែបផ្លូវភេទលើកុមារ ការផ្សាយផ្ទាល់នៃសកម្មភាពរំលោភបំពានផ្លូវភេទលើកុមារ និងវិធានការការពារដែលកើតចេញពីការប្រើប្រាស់ប្រព័ន្ធអនឡាញ។

២.៤.១១. កុមារត្រូវយល់ដឹងអំពីគោលការណ៍កិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ សិទ្ធិជាមូលដ្ឋានរបស់សិទ្ធិកុមារ ដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមាររួមមានៈ

- អនុសញ្ញាស្តីពីសិទ្ធិកុមារ អនុវត្តចំពោះកុមារគ្រប់រូប មិនថាពូជសាសន៍ សាសនា ឬសមត្ថភាពទោះជាកុមារគិត ឬនិយាយបែបណាក៏ដោយ និងមកពីប្រភេទគ្រួសារយ៉ាងណាក៏ដោយ
- ឧត្តមប្រយោជន៍របស់កុមារ ត្រូវតែជាអាទិភាពចម្បងក្នុងរឿងទាំងអស់ ដែលប៉ះពាល់ដល់កុមារ
- កុមារគ្រប់រូបមានសិទ្ធិរស់រានមានជីវិត ដែលរដ្ឋាភិបាលត្រូវតែអនុវត្តឱ្យអស់ពីសមត្ថភាពដើម្បីធ្វើឱ្យប្រាកដថា កុមាររស់រានមានជីវិត និងអភិវឌ្ឍពេញលេញ

- កុមារគ្រប់រូបមានសិទ្ធបញ្ចេញមតិចំពោះគ្រប់បញ្ហាដែលនាំឱ្យប៉ះពាល់ដល់ពួកគេ និងមានការគិតគូរយ៉ាងយកចិត្តទុកដាក់។

២.៤.១២. អាណាព្យាបាលបង្រៀនកូនឱ្យមានភាពឆ្លាតវៃ នៅពេលប្រើប្រាស់អនឡាញ រួមមាន ការមិនចែករំលែកនូវព័ត៌មានផ្ទាល់ខ្លួន ការមិនជួបផ្ទាល់ជាមួយមនុស្សចម្លែក ដែលកុមារស្គាល់តាមប្រព័ន្ធអនឡាញ ការមិនទទួលយកឯកសារ ឬរូបភាពពីមនុស្សដែលមិនស្គាល់ ការពិនិត្យមើលព័ត៌មាន ដើម្បីប្រាកដអាចជឿទុកចិត្តបាន ក៏ដូចជាការប្រាប់ដល់មនុស្សពេញវ័យ ដែលអាចទុកចិត្តបាន ប្រសិនបើគិតថា អាចមានអ្វីដែលមិនល្អអាចកើតឡើងចំពោះកុមារផ្ទាល់។

២.៤.១៣. អាណាព្យាបាលត្រូវពិនិត្យ និងសាកសួរបន្ថែមពេល ដែលពួកគេបានចំណាយពេលច្រើនលើប្រព័ន្ធអ៊ីនធឺណិត ឬញៀននឹងការប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម ឬហ្គេមកំសាន្តតាមអនឡាញ រឿងល្អបំផុត ដែលអ្នកត្រូវធ្វើ គឺនិយាយជាមួយកូនរបស់អ្នកឱ្យបានទៀងទាត់ ដើម្បីណែនាំឱ្យកាត់បន្ថយការប្រើប្រាស់អ៊ីនធឺណិត ជាពិសេស ឱ្យពួកគេចេះបែងចែកពេលវេលាក្នុងការប្រើប្រាស់អ៊ីនធឺណិត។

**២.៥. ឧស្សាហកម្ម**

២.៥.១. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សហការជាមួយស្ថាប័នអនុវត្តច្បាប់ អង្គការសង្គមស៊ីវិល និងប្រតិបត្តិករ បណ្តាញរាយការណ៍បន្ទាន់តាមអ៊ីនធឺណិត រៀបចំបទដ្ឋានបច្ចេកទេសសមស្របសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន អនុវត្ត ដើម្បីទប់ស្កាត់ការបង្ហោះ ការបញ្ជូន ការចែកចាយ ការរក្សាទុក ការផលិត និងដើម្បីលើកម្ពស់ការរាយការណ៍មាតិកាខុសច្បាប់ ឬមាតិកាមិនសមស្របតាមអាយុរបស់កុមារ និងជម្រុញការលុបចោលមាតិកា ដែលមានគ្រោះថ្នាក់ដល់កុមារមានដូចជា CSAM ជាអាទិ៍ ចេញពីប្រព័ន្ធអនឡាញ ។

២.៥.២. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ គួរលើកទឹកចិត្ត ឬណែនាំដល់ក្រុមហ៊ុនបច្ចេកវិទ្យាឱ្យប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត(AI) កម្មវិធី Photo DNA ឬ បច្ចេកវិទ្យាថ្មីៗដទៃទៀត ដូចជា Hashing Technology ដែលអាចចាប់យក និងបញ្ជូនសំណើទៅមន្ត្រីអនុវត្តច្បាប់ ឬអ្នកផ្តល់សេវាបង្ហោះមាតិកា ឱ្យធ្វើការលប់ចោលនូវសម្ភារខុសច្បាប់ ឬ CSAM ។

២.៥.៣. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បង្កើតយន្តការគ្រប់គ្រង និងសម្របសម្រួលជាមួយក្រុមហ៊ុនបច្ចេកវិទ្យាលើលក្ខណៈបច្ចេកទេស នៃប្រព័ន្ធរាយការណ៍បន្ទាន់តាមទូរស័ព្ទ និងតាមអ៊ីនធឺណិត ដើម្បីធានានូវដំណើរការរលូន និងកិច្ចសហការរវាងអ្នកពាក់ព័ន្ធ ក្នុងការឆ្លើយតបគ្រោះថ្នាក់នានាតាមប្រព័ន្ធអនឡាញចំពោះកុមារ។

២.៥.៤. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ផ្តល់គោលការណ៍ណែនាំ និងធានាឱ្យមានក្របខ័ណ្ឌគតិយុត្តិគ្រប់គ្រាន់ និងជាក់លាក់ដើម្បីជំរុញវិធានការ និងកាតព្វកិច្ចរបស់ក្រុមហ៊ុនបច្ចេកវិទ្យា

លើ ១)ការផ្សព្វផ្សាយពីសុវត្ថិភាពលើប្រព័ន្ធអនឡាញ ២)ការធានាភាពសមស្របនៃផលិតផល និងសេវាកម្មនានាចំពោះសុវត្ថិភាពកុមារ និងយុវជនជាអ្នកប្រើប្រាស់ ៣) ការផ្តល់ព័ត៌មាន និងចំណេះដឹងមូលដ្ឋានក្នុងការកំណត់សុវត្ថិភាពឧបករណ៍ ឬកម្មវិធីដែលកុមារប្រើប្រាស់ និង ៤) ការបង្កើតប្រព័ន្ធរាយការណ៍សម្រាប់អ្នកប្រើប្រាស់របស់ខ្លួនអាចចូលរាយការណ៍ពីកង្វល់ ឬការសង្ស័យទាក់ទងនឹងការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ។

២.៥.៥. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជំរុញក្រុមហ៊ុនបច្ចេកវិទ្យាឱ្យបង្កើត និងចូលរួមក្នុងកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពតាមអនឡាញ កម្មវិធីអន្តរកម្មឌីជីថល សម្រាប់កុមារ ឪពុកម្តាយ គ្រូបង្រៀន និងសាធារណជន ដែលប្រើប្រាស់សេវាកម្មរបស់ខ្លួនប្រកបដោយបរិយាបន្ន ជាពិសេសចំពោះតំបន់ជនបទដាច់ស្រយាល។

២.៥.៦. ក្រុមហ៊ុនបច្ចេកវិទ្យាគួរដាក់បញ្ចូលខ្លឹមសារ ឬការណែនាំអំពីសិទ្ធិកុមារទៅក្នុងគោលនយោបាយសាជីវកម្មរបស់ខ្លួន និងដំណើរការគ្រប់គ្រងការកំណត់ ទប់ស្កាត់ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន នៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមកលើសិទ្ធិរបស់កុមារ។

២.៥.៧. ក្រុមហ៊ុនបច្ចេកវិទ្យា និងវិស័យឯកជនដទៃទៀត គួរបង្កើតបរិយាកាសឌីជីថលឱ្យកាន់តែមានសុវត្ថិភាព និងកាន់តែរីករាយ សម្រាប់កុមារ និងយុវជនគ្រប់វ័យ តាមរយៈការដាក់ចេញវិធានការចាំបាច់នានា រួមទាំងការដាក់ឱ្យអនុវត្តគោលការណ៍សុវត្ថិភាពដោយការរចនា (Safety by Desgin) នៅក្នុងបច្ចេកវិទ្យា និងសេវាកម្មរបស់ក្រុមហ៊ុនខ្លួន។

## ២.៦. ប្រព័ន្ធផ្សព្វផ្សាយ និងទំនាក់ទំនង

២.៦.១. ក្រសួង ស្ថាប័នពាក់ព័ន្ធ លើកទឹកចិត្តឱ្យប្រព័ន្ធផ្សព្វផ្សាយ និងកម្មវិធីកម្សាន្តនានា បង្កើនការយល់ដឹងសមស្របអំពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ ហើយលើកទឹកចិត្តឱ្យមានការគាំទ្រយុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ នៅពេលសមស្របក្នុងលក្ខណៈប្រកបដោយតុល្យភាព និងការទទួលខុសត្រូវព្រមទាំងផ្តល់ព័ត៌មានគ្រប់គ្រាន់អំពីវិធានសុវត្ថិភាពតាមប្រព័ន្ធអនឡាញ។

២.៦.២. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាវិជ្ជមាន និងពិចារណាលើតម្រូវការរបស់កុមារទាំងអស់ ដោយមិនគិតពីភេទ អាយុ ប្រាក់ចំណូល ឬប្រវត្តិ។

២.៦.៣. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ លើកកម្ពស់ការយល់ដឹងអំពីការការពារកុមារតាមប្រព័ន្ធអនឡាញតាមរយៈប្រព័ន្ធផ្សព្វផ្សាយក្នុងមធ្យោបាយ ដែលងាយស្រួលសម្រាប់កុមារ។ ប្រព័ន្ធផ្សព្វផ្សាយត្រូវដឹងអំពីកិច្ចការពារកុមារតាមអនឡាញ និងត្រូវបានលើកទឹកចិត្តឱ្យគាំទ្រយុទ្ធនាការផ្សព្វផ្សាយជាសាធារណៈប្រកបដោយតុល្យភាព និងការទទួលខុសត្រូវ។

២.៦.៤. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធលើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់អ៊ីនធឺណិតទាក់ទងនឹងការកំណត់ឯកជនភាព ការរក្សាសុវត្ថិភាពតាមប្រព័ន្ធអនឡាញ និងការបិទបាំងព័ត៌មានផ្ទាល់ខ្លួនមិនឱ្យមើលឃើញជាសាធារណដល់អ្នកប្រើប្រាស់។

២.៦.៥. ក្រសួង ស្ថាប័នពាក់ព័ន្ធបង្កើតកម្មវិធីផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីបទល្មើស និងហានិភ័យពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញនៅទីប្រជុំជន និងនៅជនបទជាពិសេសនៅតំបន់ជនជាតិភាគតិច។

២.៦.៦. ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធ ផលិតសម្ភារដើម្បីបង្ការ ទប់ស្កាត់ សម្ភាររំលោភបំពានផ្លូវភេទលើកុមារ(CSAM) និងទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ និងផ្សព្វផ្សាយតាមទូរទស្សន៍ ឬបណ្ដាញសង្គមឱ្យដល់កុមារ និងយុវជន រួមទាំងសាធារណៈជន។

២.៦.៧. ក្រសួង ស្ថាប័ន វិស័យឯកជន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ បង្កើតកម្មវិធីអប់រំ ឬបណ្តុះបណ្តាលដល់ឪពុកម្តាយ អាណាព្យាបាល អ្នកថែទាំកុមារ លោកគ្រូ អ្នកគ្រូ ឱ្យយល់ដឹងពីការប្រើប្រាស់អ៊ីនធឺណិតដែលភ្ជាប់ទំនាក់ទំនងកុមារ និងយុវជនទៅនឹងប្រព័ន្ធអនឡាញ ការសន្ទនាអំពីហានិភ័យតាមអនឡាញជាមួយកុមារដោយបើកចំហតាមបែបវិជ្ជមាន និងវិធីស្វែងរកជំនួយនៅពេលកុមារជួបគ្រោះថ្នាក់នៅលើប្រព័ន្ធអនឡាញ។

២.៦.៨. ក្រសួង ស្ថាប័ន វិស័យឯកជន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ បង្កើតកម្មវិធីលើកទឹកចិត្តឪពុកម្តាយ អាណាព្យាបាល អ្នកថែទាំកុមារ លោកគ្រូ អ្នកគ្រូ និងកុមារ ឱ្យពិភាក្សាជុំវិញកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញនៅក្នុងគ្រួសារ សាលារៀន និងសហគមន៍ ដោយធានាឱ្យបាននូវការយល់ដឹងអំពីសិទ្ធិកុមារ តម្រូវការរបស់កុមារ និងហានិភ័យ។

## ៣. ការពិនិត្យតាមដាន និងវាយតម្លៃ

ការពិនិត្យតាមដាន ដើម្បីជំរុញឱ្យក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធលើការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញមាន ២កម្រិត៖

កម្រិតទី ១៖ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នឹងធ្វើការពិនិត្យតាមដានវឌ្ឍនភាពប្រចាំឆ្នាំ នៃការអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ ដោយផ្តោតលើគោលការណ៍ទាំង ៦៖ ១. គោលនយោបាយនិងអភិបាលកិច្ច ២.យុត្តិធម៌ព្រហ្មទណ្ឌ ៣.សេវាជនរងគ្រោះ ៤.សង្គម និងសហគមន៍ ៥.ឧស្សាហកម្ម និង៦.ប្រព័ន្ធផ្សព្វផ្សាយ ដែលទទួលខុសត្រូវអនុវត្តដោយក្រសួង ស្ថាប័ន វិស័យឯកជន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល។

កម្រិតទី ២៖ ក្រសួង ស្ថាប័ន វិស័យឯកជន អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធអនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិស្តីពីកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញត្រូវធ្វើការពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តរបស់អង្គភាពជំនាញ ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

## ឯកសារយោង


១. អនុសញ្ញាស្តីពីសិទ្ធិកុមារ ឆ្នាំ១៩៨៩
២. គោលនយោបាយជាតិស្តីពីប្រព័ន្ធកិច្ចការពារកុមារ ២០១៩-២០២៩
៣. ផែនការសកម្មភាពដើម្បីបង្ការ ទប់ស្កាត់ និងឆ្លើយតបការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញឆ្នាំ២០២១-២០២៥
៤. Global model child online protection 2021 (Handbook and Toolkit)
៥. Luxembourg Terminology Guideline
៦. UNICEF - Guidelines for industry on child online protection
៧. ITU and UNICEF: Guidelines for industry on child online protection 2014
៨. ព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
៩. សេចក្តីសម្រេចលេខ ១០៥ ក.ជ.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មការការពារកុមារថ្នាក់ជាតិ
១០. សេចក្តីសម្រេចលេខ ២០៣ ក.ជ.ក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសអន្តរក្រសួងដើម្បីពិនិត្យ និងផ្តល់យោបល់លើការសិក្សាស្រាវជ្រាវអំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិតនៅកម្ពុជា
១១. សេចក្តីថ្លែងការណ៍សកម្មភាពសកល (WePROTECT) នៅឆ្នាំ២០១៥
១២. សេចក្តីថ្លែងការណ៍ប្រមុខរដ្ឋនៃប្រទេសជាសមាជិកអាស៊ានឆ្នាំ២០១៩
១៣. របាយការណ៍វិភាគស្ថានភាពដំបូងស្តីពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញឆ្នាំ២០២០
១៤. យុទ្ធសាស្ត្រ INSPIRE
១៥. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយធ្វើការវិភាជន៍ធនធានបន្ថែមលើវិស័យសុខាភិបាល អប់រំ សង្គមកិច្ច និងវិស័យផ្សេងៗទៀតសម្រាប់ជំរុញការអភិវឌ្ឍធនធានមនុស្ស រួមទាំងការអភិវឌ្ឍកុមារសំដៅសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ២០១៦-២០៣០
១៦. អនុសញ្ញាក្រុមប្រឹក្សាអឺរ៉ុបស្តីពីកិច្ចការពារកុមារប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានផ្លូវភេទ ឆ្នាំ២០០៧
១៧. សេចក្តីសម្រេចនៃមហាសន្និបាតអង្គការសហប្រជាជាតិ ៦៨/១៦៧ ស្តីពីសិទ្ធិចំពោះឯកជនភាពនៅក្នុងសករាជឌីជីថលបញ្ជាក់អំពីឯកជនភាព និងសិទ្ធិក្នុងការបញ្ចេញមតិយោបល់ ដោយមិនទទួលរងការជ្រៀតជ្រែកដោយខុសច្បាប់
១៨. សេចក្តីសម្រេចនៃក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ៣២/១៣ ស្តីពីការលើកកម្ពស់កិច្ចការពារ និងការប្រើប្រាស់សិទ្ធិមនុស្សនៅលើប្រព័ន្ធអ៊ីនធឺណិត។

KINGDOM OF CAMBODIA
National Religion King

# NATIONAL GUIDLINE
# ON ONLINE CHILD PROTECTION

Prepared by
Cambodian National Council for Children
2023

*Translate only*

# FOREWORDS

The last two decades, achieved steady economic growth. Currently, Cambodia is integrating itself into the region and the world, giving Cambodia ample opportunities to build and develop the country. Moreover, Cambodia is ready to participate in the Fourth Industrial Revolution, focusing in particular on the technology that the world is effectively using for political, economic and social purposes. Advances in information technology have spurred the growth of jobs, politics, economy and society, making Cambodia more connected to countries in the region and the world.

Advances in information technology are creating online child sexual exploitation, a new form that is spreading around the world, including Cambodia. Connecting to the Internet, personal computers and smartphones in the community offer many social and economic benefits. At the same time, it poses a risk to children and young people who are high-speed internet users and actively involved in social media. The proliferation of internet connectivity has made it easier and faster for internet users to access CSAM and to disseminate materials to support child sex goers among third gender and those who have sexual interest with children.

